ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**
**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
លេខ: ០៤៧..សអជ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**តាមរយៈ** ឯកឧត្តមអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ

**កម្មវត្ថុ:** របាយការណ៍កិច្ចប្រជុំគណៈកម្មាការអនុវត្តគម្រោង (IC) លើកទី ៧ ថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១១

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា គណៈកម្មាការអនុវតគម្រោង (IC) លើកទី ៧ បានរៀបចំឡើងនាថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១១ នៅក្រសួងពាណិជ្ជកម្មក្រោមអធិបតីភាពរបស់ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង ជាប្រធានគណៈកម្មាការអនុវត្តគម្រោង ដោយមានសមាជិកគណៈកម្មាការ មកពីក្រសួងស្ថាប័នពាក់ព័ន្ធ (ដូចមានភ្ជាប់ជូនឧបសម្ព័ន្ធ I) ដើម្បីពិភាក្សាលើរបៀបវារៈ ពិនិត្យ និង ផ្តល់ការយល់ព្រមលើគម្រោងយុទ្ធសាស្ត្រលំអិតចំនួន ៣ ដែលបានអនុម័តរួចហើយ និង ជ្រើសរើសគម្រោងយុទ្ធសាស្រថ្មីមួយទៀតសម្រាប់អនុម័តនៅត្រីមាសទី១ ឆ្នាំ២០១១ ដើម្បីឆ្លើយតបតាមរបាយការណ៍ Mid-Term Review (MRT) ។

<u>របៀបវារៈកិច្ចប្រជុំ និងចំនុចសំខាន់ៗ បានពិភាក្សារួមមាន:</u>

- ការធ្វើបទបង្ហាញលំអិតអំពីគម្រោង យុទ្ធសាស្ត្រចំនួន ៣ ដែលបានអនុម័តរួចហើយ
- ការធ្វើបទបង្ហាញសង្ខេបអំពីគម្រោងយុទ្ធសាស្រថ្មី ១ សម្រាប់អនុម័តនៅត្រីមាសទី១ ឆ្នាំ២០១១
- ការធ្វើបទបង្ហាញអំពីការរីកចម្រើន ផែនទីបង្ហាញផ្លូវសរសស្តម្ភទី ១ និង ទី៣
- បញ្ហាផ្សេងៗ

បន្ទាប់ពីលោក ឈៀង ពេជ្រ ប្រធាននាយកដ្ឋានស្ថិតិ និង ក្រុមការងារជំនាញ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ធ្វើបទបង្ហាញពីគម្រោងយុទ្ធសាស្ត្រលំអិតទាំង ៣ និង ការធ្វើបទបង្ហាញសង្ខេបអំពីគម្រោងយុទ្ធសាស្រថ្មី ១ សម្រាប់អនុម័តនៅត្រីមាសទី១ ឆ្នាំ២០១១ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ II) កិច្ចប្រជុំបានធ្វើការពិភាក្សា និងឆ្លើយតបចំពោះសំណួរយ៉ាងល្អិតល្អន់។ ជំនួសមុខគណៈកម្មាការ អនុវត្តគំរោង (IC) ឯកឧត្តម ប៉ាន សូរស័ក្តិ ធ្វើការបូកសរុបជាលទ្ធផលរួម ដូចខាងក្រោម:

១/សំរេចឯកភាព អំពីគម្រោងយុទ្ធសាស្ត្រលំអិតចំនួន ៣ គឺ ការវិភាគពត៌មានសង្វាក់តម្លៃ (Value Chain Information Unit) ផែនការមេអំពីប្រព័ន្ធអេឡិចត្រូនិច សម្រាប់ក្រសួងពាណិជ្ជកម្ម (ICT Master Plan Implementation) និង កម្មវិធីពង្រឹងសមត្ថភាពស្ថាប័នអគ្គនាយកដ្ឋានគយ-រដ្ឋាករកម្ពុជា (CDCE Capacity Enhancement Program) ។

២/សំរេចឯកភាព អំពីការជ្រើសរើសគម្រោងយុទ្ធសាស្រថ្មី ១ គឺ កម្មវិធីពង្រឹងសមត្ថភាពភ្នាក់ងារអនុវត្តគម្រោងទាំងអស់ (Implementing Agencies Capacity Enhancement Program)

៣/ ការទទួលដឹងលឺអំពីការរីកចម្រើន ផែនទីបង្ហាញផ្លូវសរសស្តម្ភទី ១ និង ទី៣

៤/ ចំពោះគម្រោងដែលបានដាក់កន្លងមក និង គម្រោងថ្មីនានា ដែលមិនទាន់អនុម័តដោយគណៈកម្មាការអនុវត្តគំរោង (IC) និង អនុគណៈកម្មាការអភិវឌ្ឍនិពាណិជ្ជកម្ម-វិនិយោគពាក់ពន្ធ័វិស័យពាណិជ្ជកម្ម (SSC-TD.TRI) នឹងត្រូវពិនិត្យឡើងវិញ អោយសមស្រប តាមកម្មវត្ថុគម្រោងគាំទ្រការអភិវឌ្ឍនិពាណិជ្ជកម្ម (TDSP) ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១ម៉១៥នាទី ក្នុងបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលល្អ ។

សេចក្តីដូចបានជំរាបជូនខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងផ្តល់ការណែនាំដោយ សេចក្តីអនុគ្រោះ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

អ្នកធ្វើរបាយការណ៍

**ហង់ សុជីវិន**

<u>ចំលងជូន</u>

-ឯ.ឧ ប្រធាន-អនុប្រធាន និង សមាជិកគណៈកម្មាការ អនុវត្តគំរោង

បានឃើញ និង ឯកភាព

គោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**

**ចាន់ សុរស័ក្តិ**